**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

លេខ: ០១៧/០៨ ក.ណ អ.គ.គ

## កំណត់ហេតុ កិច្ចប្រជុំ ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីពាន់ប្រាំបី ខែ កុម្ភៈ ថ្ងៃទី ម្ភៃប្រាំ វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសាលប្រជុំ C15 នៃទីស្ដី ការគណៈរដ្ឋមន្ត្រី (អតីតរដ្ឋសភាចាស់) មានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពរបស់ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពិនិត្យ និងពិភាក្សាបន្តលើកិច្ចការ របស់ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្ដើមឯកឧត្តម សំ សុខផល បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍មួយចំនួន និងមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនោះ ។ ជាបន្ទាប់ឯកឧត្តមបានមានប្រសាសន៍ថា កិច្ចប្រជុំថ្ងៃនេះ គឺដើម្បីពិនិត្យមើល និងតាមដានជាបន្តទៅលើ សូចនាករតាមដានរួម ( JMI )ដែលពាក់ព័ន្ធដល់កំណែទម្រង់ច្បាប់ និងតុលាការ ។

ក្នុងពេលនោះ ឯកឧត្តមបានធ្វើរបាយការណ៍សង្ខេបស្ដីពីស្ថានភាពច្បាប់ទាំងប្រាំបី ដែលជាសូចនាករ តាមដានរួម គឺ ៖

១- ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុម័តរួចហើយ
២- ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តហើយ
៣- ក្រមរដ្ឋប្បវេណី ត្រូវបានសភាអនុម័តហើយ ប៉ុន្តែមិនទាន់បានអនុវត្តនៅឡើយទេ គឺកំពុងតែធ្វើការផ្សព្វផ្សាយ
៤- សេចក្ដីព្រាងក្រមព្រហ្មទណ្ឌកំពុងត្រូវបានធ្វើការពិនិត្យជាចុងក្រោយ ដោយក្រុមការងារបច្ចេកទេស មួយក្រុមរបស់ក្រុមប្រឹក្សាអ្នកច្បាប់ មុនពេលដាក់ជូនទៅអន្តរក្រសួង ។
៥- សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានពិនិត្យរួចដោយក្រុមប្រឹក្សាអ្នកច្បាប់
៦- សេចក្ដីព្រាងច្បាប់ចាត់តាំងតុលាការ កំពុងតែព្រាងនៅឡើយ

៧- ច្បាប់ប្រឆាំងអំពើពុករលួយ គឺកំពុងស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានពីក្រសួងទំនាក់ទំនង សភា និងអធិការកិច្ចនៅឡើយ

៨- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម កំពុងតែត្រួតពិនិត្យដោយក្រសួងយុត្តិធម៌ ។

ក្នុងឱកាសនោះឯកឧត្តមបានធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំ អំពីការប្រជុំរបស់អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ ថ្មីៗនេះ ដោយលើកឡើងអំពីតួនាទី និងភារកិច្ចក្នុងការតាមដាននៃការអនុវត្តសកម្មភាពរយៈពេលខ្លី និងមធ្យមរបស់កម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រ ទាំង៧នៃកំណែទម្រង់ច្បាប់ និងតុលាការ ហើយនៅក្នុងការប្រជុំនោះផងដែរ នៅមានបញ្ហាមួយចំនួនដូចខាងក្រោមនេះ ៈ

- អំពីភាពយឺតយ៉ាវនៃការពិនិត្យឡើងវិញនូវច្បាប់ទាក់ទងនឹងវិស័យតុលាការ
- អំពីតួនាទីរបស់នគរបាលយុត្តិធម៌ ជាមួយនិងព្រះរាជអាជ្ញា
- អំពីការធ្វើយ៉ាងណាដើម្បីអោយមានការសម្របសម្រួល ទាក់ទងជាមួយតួនាទីនៃអគ្គាធិការរបស់ក្រសួងយុត្តិធម៌ និងអគ្គាធិការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំងបានស្វែងរកដំណោះស្រាយរួមទាក់ទងនឹងបញ្ហាផ្សេងៗទៀត ។

បន្ទាប់ពីបានបញ្ចប់នូវរបាយការណ៍សង្ខេប ស្តីពីស្ថានការស្ងួចនាករទាំងប្រាំពីររួចមក ឯកឧត្តមប្រធានបានអញ្ជើញលោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុុត្តិធម៌ ធ្វើសេចក្តីរាយការណ៍បន្ថែមអំពីស្ថានភាពច្បាប់សំខាន់ៗ របស់ក្រសួងយុត្តិធម៌ដែលបានធ្វើសេចក្តីព្រាង និងអនុម័តកន្លងមក ។

លោកជំទាវបានមានប្រសាសន៍ថា ក្នុងចំណោមក្រុមទាំង៤ខាងលើនោះ មានក្រុមពីរដែលបានអនុវត្តទូទាំងប្រទេសហើយ គឺក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ។

-ច្បាប់ស្តីពីការជាកពិន័យស៊ីវិល បានអនុម័តដោយគណៈរដ្ឋមន្ត្រី

-ពេលថ្មីៗនេះច្បាប់ស្តីពីការជួញដូរមនុស្ស ត្រូវបានអនុម័ត និងឡាយព្រះហស្ថដោយព្រះមហាក្សត្រ ។

-ច្បាប់ស្តីអំពីការតំកល់កំពុងតែត្រូវបានព្រាងដោយ ក្រសួងនឹងសហការជាមួយជំនាញការ JICA ។

ឯកឧត្តម សំ សុខផល បានបញ្ជាក់បន្ថែមថា ច្បាប់ដែលបានលើកឡើងខាងលើ គឺទាក់ទងទៅនឹងប្រព័ន្ធស្ងួចនាករ ចំណែកឯច្បាប់ស្តីពីច្បាប់ផាកពិន័យស៊ីវិលជាច្បាប់បន្ទាប់បន្សំប៉ុណ្ណោះ ដូច្នេះមិនគួរដាក់បញ្ចូល ទៅក្នុងច្បាប់មូលដ្ឋានទាំងប្រាំបីនោះទេ ។

លោក Pierre Espieu, Chef de project, Appui à L' Etat de Droit, France មានចម្ងល់ថា ច្បាប់ប្រឆាំង នឹងអំពើពុករលួយបានធ្វើសេចក្តីព្រាងរួចរាល់ហើយ ប៉ុន្តែហេតុអ្វីបានជាច្បាប់នេះកំពុងស្ថិតនៅក្នុងក្រសួង ទំនាក់ទំនងសភា និងអធិការកិច្ចទៅវិញ ?

ឆ្លើយតបទៅនឹងសំណួរនេះ ឯកឧត្តម សំ សុខផល បានមានប្រសាសន៍ថា ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ចជាអ្នកទទួលបន្ទុកក្នុងរឿងនោះ ឯកឧត្តមប្រធានផ្ទាល់ ក៏ពុំបានដឹងអំពី

ស្ថានការណ៍នៃច្បាប់នោះដែរ ។ ហើយទាក់ទងនឹងច្បាប់ប្រឆាំងអំពើពុករលួយនេះដែរ ឯកឧត្តមប្រធាន ក៏បានអញ្ជើញតំណាងអង្គភាពប្រឆាំងអំពើពុករលួយ ដែលបានចូលរួមប្រជុំនាថ្ងៃនោះ ដើម្បីធ្វើការស្រាយបំភ្លឺជូនអង្គប្រជុំ ។

ឯកឧត្តម យាង សេង តំណាងអង្គភាពប្រឆាំងអំពើពុករលួយ បានជម្រាបជូនអង្គប្រជុំថា ស្ថាប័នរបស់លោកគ្រាន់តែជាអ្នកអនុវត្តច្បាប់តែប៉ុណ្ណោះ គឺមិនមែនជាអ្នកអនុម័តច្បាប់នោះទ្បើយ ។

ឯកឧត្តម សំ សុខផល បានធ្វើការបំភ្លឺថា ចំពោះច្បាប់ប្រឆាំងអំពើពុករលួយនេះ យើងមានបញ្ហាបច្ចេកទេស មួយចំនួន ត្រូវរង់ចាំការអនុម័តក្រមព្រហ្មទណ្ឌជាមុនសិន ។ ជាមួយគ្នានោះផងដែរ ឯកឧត្តម ស៊ុយ ម៉ុងលាង ប្រធានអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានលើកយកអនុសាសន៍របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧ ក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាថា ទាក់ទងនឹងច្បាប់ប្រឆាំងអំពើពុករលួយនេះ បើសិនជាមានដៃគូអភិវឌ្ឍន៍ ឬសហគមន៍ប្រទេសអ្នកផ្តល់ជំនួយ ចង់ដឹងពីស្ថានភាពនៃច្បាប់នេះថាយ៉ាងណាៗនោះ អាចសួរឯកឧត្តមបាន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ ឯកឧត្តមបានបញ្ជាក់ទៀតថា ចំពោះក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុក រលួយនេះ មានការពាក់ព័ន្ធគ្នាមិនអាចដាក់ដោយឡែកបានទេ ។

ឯកឧត្តម សំ សុខផល បានបញ្ជាក់បន្ថែមថា សេចក្តីព្រាងក្រមព្រហ្មទណ្ឌកំពុងត្រូវបានពិនិត្យជាចុងក្រោយ ដោយក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានឯកឧត្តម ហេង ជី ជាប្រធានក្រុមការងារនេះផ្ទាល់ ។

លោក Pierre Espieu បានចោទជាសំណួរសួរថា តើឯកឧត្តមប្រធានអាចជម្រាបជូន អង្គប្រជុំបានដែរទេ អំពីស្ថានភាពសេចក្តីព្រាងដែលជូនទៅសភានៅពេលនេះ ? ព្រោះនៅពេលបោះឆ្នោតសភានឹងផ្អាកការប្រជុំ ហើយសំណួរមួយទៀត គឺ តើការប្រជុំរបស់សភានៅថ្ងៃបន្ទាប់នោះនៅពេលណា ?

ឯកឧត្តម សំ សុខផល បានមានប្រសាសន៍ថា សភាអាចនឹងឈប់សំរាកនៅពេលមុនចូលឆ្នាំខ្មែរ ប៉ុន្តែនៅពេលណាក្រមព្រហ្មទណ្ឌឆ្លងគណៈរដ្ឋមន្ត្រីហើយ យើងអាចផ្ទៀងផ្ទាត់ជាមួយច្បាប់ផ្សេងទៀត ដូចជា ច្បាប់ប្រឆាំងអំពើពុករលួយជាដើម ។ ជាបន្ទាប់ លោក Pierre Espieu បានសួរទៀតថា តើថ្ងៃណាសភាថ្មី នឹងធ្វើការកោះប្រជុំលើកទី១ ?

ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ថា សភាថ្មីអាចនឹងកោះប្រជុំលើកទីមួយរបស់ខ្លួន នៅចុងខែ សីហា ឬ នៅដើមខែ កញ្ញា ឆ្នាំ ២០០៨ ខាងមុខនេះ។

លោក Pierre Espieu បានសួរជាចុងក្រោយថា តើច្បាប់មួយក្នុងចំណោមច្បាប់ជាមូលដ្ឋានទាំងប្រាំបី ដែលត្រូវបញ្ជូនទៅសភានោះ សភាអាចអនុម័តបានចាប់តាំងពីពេលនេះ ឬក៏ត្រូវរង់ចាំរហូតដល់ខែ តុលា ឆ្នាំ ២០០៨ បន្ទាប់ពី ធ្វើការបោះឆ្នោតរួច ?

ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ថា ពេលវេលាមិនមែនជាចំណោទទេ ការសំខាន់នោះគឺ ការដែល រដ្ឋាភិបាលត្រូវការអនុម័តច្បាប់នោះដំណើរការនឹងជឿនលឿនទៅមុខហើយ ។

ជាបន្ទាប់ ឯកឧត្តមប្រធានបានសុំឱ្យអ្នកសម្របសម្រួលអនុក្រុមធ្វើរបាយការណ៍ ស្តីពីការជឿនលឿន របស់កម្មវិធីសម្រាប់ការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការនៃអនុក្រុមនីមួយៗដូចតទៅ ៖

អនុក្រុមទី១ មានលោក Ben Schultz, CCJAPIII បានលើកយកបញ្ហាមួយ ដែលទាក់ទងនឹងកង្វះភាពជឿនលឿនពាក់ព័ន្ធនឹងការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា ។ ក្នុងបញ្ហានេះអនុក្រុមទីមួយបាន ជួបខាងតំណាងក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃផងដែរ ដើម្បីសួរយោបល់អំពីការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យានេះ ។

ជាចុងក្រោយសមាជិកអនុក្រុមរបស់យើងបានសម្រេចថា ចង់អោយមានការរៀបចំធ្វើ សិក្ខាសាលាមួយ ដើម្បីស្រង់យកនូវយោបល់ល្អៗក្នុងការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យានេះ ។

លោក កុយ នាម តំណាង UNDP បានធ្វើការរាយការណ៍ ទាក់ទងនឹងការដោះ ស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ដែលមានការសហការពីក្រសួង យុត្តិធម៌ និងក្រសួងមហា ផ្ទៃ ។ មានការពង្រីកមណ្ឌលសេវាកម្មយុត្តិធម៌ ពី ៤ទៅ២០ស្រុក (ពី ៤ទៅ៦ខេត្ត) ។ ការងារដ៏ទៃទៀតមានរួម បញ្ចូលការពង្រឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយមានការពង្រីកពី ២០ទៅ៥៦ឃុំ ។ ចំណែកសកម្មភាពពង្រឹងសមត្ថភាព ស្ត្រីនៅថ្នាក់ភូមិ ត្រូវបាន ពង្រីក ពី២២ទៅ៨០ភូមិ ។ ការបង្កើនការយល់ដឹងអំពីច្បាប់ និង ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដល់ជនជាតិភាគ តិចក៏ត្រូវបានពង្រឹងដែរ ។

លោកស្រី Kana Manabe តំណាង JICA និងជាអ្នកសម្របសម្រួលរបស់អនុក្រុមទី២ បានធ្វើការបកស្រាយ អំពីចំណុចទី១ដែលទាក់ទងនឹងភាពស៊ីសង្វាក់គ្នានៃច្បាប់ ។ ថ្វីត្បិតតែមានការខិតខំយ៉ាងនេះហើយតែ JICA បានពិនិត្យមើលឃើញថា ពុំមានភាពស៊ីសង្វាក់គ្នារវាងច្បាប់ ពាណិជ្ជកម្មជាមួយនឹងក្រមរដ្ឋប្បវេណីនៅឡើយ ។ លោកស្រីបានស្នើសុំអោយក្រុមការងារបច្ចេកទេស ឬក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជួយពង្រឹងរចនាសម្ព័ន្ធ ដើម្បីអោយ ច្បាប់ទាំងនោះ មានលក្ខណៈស្របគ្នា និងស៊ីសង្វាក់គ្នាផង ។

JICA បានជូនដំណឹងដល់អង្គប្រជុំអំពីគម្រោងថ្មីៗទាក់ទងនឹងសកម្មភាពវិស័យកែទម្រង់ច្បាប់ និងតុលាការ របស់ JICA ៖

1- គម្រោងទី១ គឺការធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ដើម្បីអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណីមានរយៈពេល៤ឆ្នាំ ដែល JICA បានចុះហត្ថលេខាជាមួយក្រសួង យុត្តិធម៌កាលពីខែមេសា
2- គម្រោងទី២ គឺការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ និងច្បាប់ស្តីពីការតំកល់

3- គម្រោងទី៣ គឺការជួយបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញានៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អំពីបញ្ហារដ្ឋប្បវេណីមានរយៈពេល៩ឆ្នាំ ដែលនឹងចាប់ផ្តើមនៅខែមេសា
4- គម្រោងទី៤ គឺការជួយដល់គណៈមេធាវី និងមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី ក្នុងការធ្វើការបណ្តុះបណ្តាលឱ្យមានភាពប្រសើរឡើង ។ គម្រោងនេះនឹងបន្តរហូតដល់ខែ មិថុនា ឆ្នាំ ២០០៩ ។

លោក Pierre Espieu បានមានប្រសាសន៍ទាក់ទងនឹងច្បាប់ពាណិជ្ជកម្ម ដោយបានជម្រាបថា លោកបានទៅជួបជាមួយខាងក្រសួងពាណិជ្ជកម្មទៅតាមការស្នើសុំ ហើយខាងក្រុមការងារយើងបានផ្តល់នូវមតិយោបល់ហើយ ប៉ុន្តែអ្វីដែលលោកបានដឹង គឺច្បាប់ពាណិជ្ជកម្មត្រូវបានធ្វើរួចរាល់ហើយតាមរយៈ សារព័ត៌មានទៅវិញ ។

ឯកឧត្តម សំ សុខផល : ទាក់ទងនឹងច្បាប់ពាណិជ្ជកម្មនេះ ឯកឧត្តមប្រធានបានមានប្រសាសន៍ថា ឯកឧត្តមផ្ទាល់ អាចសរសេរជាលិខិតមួយផ្ញើទៅក្រសួងពាណិជ្ជកម្ម ប្រសិនបើអនុក្រុមទី២ចង់ជួប ។

លោក Mr. Rajan Shah (Access to Justice Advisor) EWMI និងជាអ្នកសម្របសម្រួលអនុក្រុមទី៤ បានធ្វើការរាយការណ៍យ៉ាងសង្ខេបទាក់ទិននឹងអនុក្រុមទី៤ ដោយលោកបញ្ជាក់ថា កាលពីថ្ងៃ ពុធ ទី២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ នេះ អនុក្រុមរបស់លោកនឹងធ្វើការកោះប្រជុំដើម្បីពិភាក្សា គម្រោងតុលាការគំរូនៅកម្ពុជាទាក់ទងនឹងវិជ្ជាជីវៈផ្នែកច្បាប់ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានធ្វើការរាយការណ៍ទាក់ទងនឹងការវិវត្តន៍ស្តីពីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ដោយលើកយកចំណុចសំខាន់ៗដែលក្រុមប្រឹក្សាបានធ្វើរួច ៖

- ទាក់ទងនឹងស្ថានភាពនៃការអនុវត្តផែនការសកម្មភាពកំណែទម្រង់ច្បាប់ក្នុងឆ្នាំ ២០០៧ ដោយ មានផ្ញើជូនតាមអ៊ីមែលដល់ភាគីពាក់ព័ន្ធនូវគំនូសតារាង ស្តីពីភាពជឿនលឿននៃការអនុវត្តសកម្មភាពជា អាទិភាពដោយកំណត់ជាភាគរយនៃការសម្រេចបាន ។
- អង្គភាពគ្រប់គ្រងគម្រោងនឹងធ្វើបច្ចុប្បន្នភាពលើតារាងនៃភាពជឿនលឿននេះ ជារៀងរាល់ បីខែម្តង ហើយនឹងមានផ្សព្វផ្សាយតាមវិបសាយរបស់ខ្លួនផងដែរ ។

ឯកឧត្តមបានលើកយកសមិទ្ធផលខ្លះៗនៃទិសដៅជាយុទ្ធសាស្ត្រទាំង៧របស់កំណែទម្រង់ច្បាប់ និង តុលាការ ដែលមានជាអាទ៍ ៖

១- យុទ្ធសាស្ត្រទី១ ដែលមានការបង្កើតព័ត៌មាន Database ក្នុងវិបសាយរបស់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។
២- យុទ្ធសាស្ត្រទី២ ឯកភាពតាមប្រសាសន៍លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌

ដែលបានលើកឡើងនៅខាងដើមស្តីពីការអនុម័តច្បាប់ផ្សេងៗទៀតក្រៅពីច្បាប់ដែលតម្រូវនៅ ក្នុងសូចនាករតាមដានរួម

៣-យុទ្ធសាស្ត្រទី៣ UNDP និងកិច្ចសហប្រតិបត្តិការបារាំងដែលជួយខាងរាជកិច្ច អោយមានការប្រសើរឡើងបច្ចុប្បន្ននេះ គឺកិច្ចសហប្រតិបត្តិការបារាំង ជាអ្នកធ្វើពង្រាងអនុក្រិត្យ ហើយនៅពេលដែលអនុក្រិត្យបានអនុម័តហើយ ខាង UNDP ជាអ្នកជួយខាងបច្ចេកទេស ។ ការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការកំពូល និងតុលាការថ្នាក់ទាប កំពុងតែប្រព្រឹត្តទៅជាធម្មតា ។

៤- យុទ្ធសាស្ត្រទី៤ : ទាក់ទងនឹងជំនួយផ្នែកច្បាប់ ឯកឧត្តមមានប្រសាសន៍ថា មិនទាន់មានអ្វីជម្រាបជូនទេ គឺរង់ចាំថវិកាពី EWMI ។

៥- យុទ្ធសាស្ត្រីទី៥ : តំណាង DIHR ដែលមានវត្តមាននៅទីនេះ គឺមានទំនាក់ទំនងជាមួយគម្រោងតុលាការគំរូ ។ ថ្ងៃស្អែកនឹងមានការប្រជុំមួយរវាងអ្នកឯកទេស អន្តរជាតិដើម្បីធ្វើការវិភាគលើស្តង់ដារ និងលក្ខណៈវិនិច្ឆ័យនៃតុលាការគំរូ។ នៅថ្ងៃទី២៨ នឹងមានប្រជុំនៃក្រុមការងារបច្ចេកទេស សម្រាប់គម្រោងតុលាការគំរូ ។

៦- យុទ្ធសាស្ត្រទី៦ : ព័ត៌មានសម្រាប់ទិសដៅជាយុទ្ធសាស្ត្រទី៦នេះត្រូវបានផ្តល់ដោយអ្នកសម្រប សម្រួលអនុក្រុមទី១រួចហើយ ។

៧- យុទ្ធសាស្ត្រទី៧ : យើងមានគម្រោងមួយទាក់ទងនឹងសូចនាករតាមដានរួម ដែលមានដំណើរការល្អដោយមានការគាំទ្រពី DANIDA និង AUSAID ។ ក្នុងនោះដែរ ឯកឧត្តមបានជម្រាបថា យើងនឹងចូលរួមកិច្ចប្រជុំមួយស្តីអំពីសេចក្តីថ្លែងការទីក្រុងប៉ារីស ដែលមានខ្លឹមសារពាក់ព័ន្ធពីការផ្តល់ជំនួយ ឧបត្ថម្ភដោយប្រសិទ្ធិភាព ដែលនឹងប្រព្រឹត្តទៅនៅ CDC។

ទីបញ្ចប់ ឯកឧត្តម សំ សុខផល បានថ្លែងអំណរគុណចំពោះការចូលរួម ពិគ្រោះយោបល់ក្នុងអង្គប្រជុំទាំងមូល និងសម្រេចថា កិច្ចប្រជុំនេះនឹងបន្ត ធ្វើនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ ខាងមុខនេះ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងបួន និងសែសិបប្រាំនាទីល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨*

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង | អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង | សេង វ៉ាន់ដា ស៊ុន សិរីវុធ